**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/១/០៧-០៩-២០០៩-អវតក-កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | **សហព្រះរាជអាជ្ញាជាតិ** |
| **ភាសាដើម** | : | ខ្មែរ |

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Sep-2017, 14:22
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# ដីកាសន្និដ្ឋានស្ថាពរ
# ទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង

---

**អ្នកដាក់ឯកសារ**

**សហព្រះរាជអាជ្ញាជាតិ**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**ចម្លងជូន**

**សហព្រះរាជអាជ្ញាអន្តរជាតិ**

លោក Nicholas KOUMJIAN

**មេធាវីការពារក្ដី អ៊ឹម ចែម**

ប៊ិត ស៊ាងលីម

Wayne JORDASH

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

| | | |
|---|---|---|
| ជេត វណ្ណលី | វ៉ែន ពៅ | Laure DESFORGES NZEPA |
| ហុង គឹមសួន | Linda BEHNKE | Ferdinand DJAMMENNZEPA |
| គីម ម៉េងឃី | Herve DIAKIESE | Martine JACQUIN |
| ឡោ ជុនធី | Nicole DUMAS | Christine MARTINEAU |
| សំ សុគង់ | Isabelle DURAND | Barnabe NEKUI |
| ស៊ិន ស៊ីវ៉ន | Françoise GAUTRY | Lyma NGUYEN |
| ទី ស្រីណា | Emmanuel JACOMY | Beini YE |

## ១. សេចក្តីផ្តើម

1. ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធានផ្ទៃក្នុង[1] ក្នុងគោលបំណងដើម្បីឱ្យសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរ។ យោងតាមវិធាន៦៦(៥) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសម្អាងហេតុ ហើយត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ។

## ២. ប្រវត្តិនីតិវិធី

### ក-ការខ្វែងយោបល់របស់សហព្រះរាជអាជ្ញា

2. ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានពិភាក្សាគ្នាលើបញ្ហាខ្វែងយោបល់គ្នា អំពីការប្តឹងចោទជនសង្ស័យថ្មីបន្ថែមទៀត ផ្សេងពីជនសង្ស័យដែលមានស្រាប់នៅ អ.វ.ត.ក ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ឱ្យបើកការស៊ើបសួរ។ ក្នុងនោះ ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមានបំណងដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីពីរឱ្យបើកការស៊ើបអង្កេតលើជនសង្ស័យបន្ថែមសម្រាប់សំណុំរឿងលេខ០០៣ និងលេខ០០៤។ ចំណែកឯសហព្រះរាជអាជ្ញាជាតិ មានជំហរមិនឯកភាពក្នុងការបើកឱ្យមានការស៊ើបអង្កេតលើជនសង្ស័យបន្ថែមផ្សេងពីជនសង្ស័យដែលមានស្រាប់នៃសំណុំរឿងលេខ០០១ និងលេខ០០២ នោះឡើយ[2]។

3. សហព្រះរាជអាជ្ញាអន្តរជាតិបានសម្រេចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈអំណះអំណាងជាលាយលក្ខណ៍អក្សរ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨[3] បញ្ជូនទៅការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក។

---

[1] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D304 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ របស់សហចៅក្រមស៊ើបអង្កេត។

[2] កំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ លើការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែមចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

[3] អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន ៧១.២។

នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ការិយាល័យរដ្ឋបាលបានថតចម្លងឯកសារនេះ រួចបញ្ជូនមកសហព្រះរាជអាជ្ញាជាតិ ស្របតាមវិធាន ៧១.២ នៃវិធានផ្ទៃក្នុង[4]។

4. នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាជាតិបានដាក់ចម្លើយតបទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា[5] ជូនអង្គបុរេជំនុំជម្រះ ស្របតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងតាមវិធាន ៧១.២ នៃវិធានផ្ទៃក្នុង បន្ទាប់ពីអង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំពន្យារពេល ក្នុងការដាក់ចម្លើយតបរួចមក។ ក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាជាតិបានលើកឡើងអំពីមូលហេតុនានា ដែលសហព្រះរាជអាជ្ញាជាតិមិនឯកភាពជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី (សំណុំរឿងលេខ០០៣ និងលេខ០០៤) របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

5. នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់ជូនសេចក្តីសន្និដ្ឋានបន្ថែមប្រសិនបើមាន ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីនៃករណីខ្វែងយោបល់គ្នា[6]។

6. កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះថា "គាត់ពុំមានសេចក្តីសង្កេតបន្ថែម លើសពីសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលមានរួចស្រេចហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលបានដាក់កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ទេ"។[7] ចំណែកឯសហព្រះរាជអាជ្ញាជាតិ បានដាក់ឯកសារដែលទាក់ទងនឹងកិច្ចពិភាក្សារបស់រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អំពីការបង្កើត អ.វ.ត.ក។

[4] វិធាន ៧១.២ នៃវិធានផ្ទៃក្នុង។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១.២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៨។

[6] សេចក្តីអញ្ជើញសហព្រះរាជអាជ្ញាឱ្យដាក់សេចក្តីសន្និដ្ឋានបន្ថែម ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះឱ្យដាក់សេចក្តីសន្និដ្ឋានបន្តទៀត ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

7. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម និងដីកាកំណត់កាលបរិច្ឆេទសវនាការ ដល់សហព្រះរាជអាជ្ញាទាំងពីរ ដោយមានភ្ជាប់នូវសេចក្តីសង្កេត និងសំណួរមួយចំនួន ដើម្បីឲ្យសហព្រះរាជអាជ្ញាទាំងពីរឆ្លើយបំភ្លឺ[8]។

8. សហព្រះរាជអាជ្ញាជាតិ បានដាក់ចម្លើយតបទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ និងសេចក្តីសង្កេតបន្ថែម កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩[9] ដែលក្នុងនោះសហព្រះរាជអាជ្ញាជាតិ បានប្រកាន់ជំហរថា គ្មានយុត្តាធិការបុគ្គលលើជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ។ មានន័យថាជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងពីរខាងលើនេះ មិនមែនជា "មេដឹកនាំជាន់ខ្ពស់" និងមិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

9. អង្គបុរេជំនុំជម្រះ មិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នានោះទេ។[10]

10. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា នៅពេលដែលអង្គបុរេជំនុំជម្រះ មិនអាចឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នាដែលបាននាំយកមកដោះស្រាយនៅចំពោះមុខខ្លួននោះ យោងតាមវិធាន ៧១(៤) នៃវិធានផ្ទៃក្នុង គឺមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៣.១ នៃវិធានផ្ទៃក្នុង។[11]

11. ដោយអនុលោមតាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស្របតាមវិធាន៧១ នៃវិធានផ្ទៃក្នុង[12] នៅថ្ងៃទី០៧

---

[8] សេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែម និងដីកាកំណត់កាលបរិច្ឆេទសវនាការរបស់ អ.ប.ជ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៩។

[9] ចម្លើយតបទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ (ឯកសារលេខ D១៧)។

[10] ឯកសារលេខ D1/1.1 និង D1/1.3 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[11] ឯកសារលេខ D1/1.1 ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

[12] ឯកសារ **D1/1.3** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿងលេខ០០៣ និងលេខ០០៤ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរលើសំណុំរឿងទាំងពីរនេះ[13]។

## ខ-ការដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ

12. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ[14] ពីបទល្មើសខាងក្រោម៖

-ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦៖ តាមមាត្រា ៥០១ និង ៥០៦ (មនុស្សឃាត) ។ ការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានចែងនៅក្នុងមាត្រា ៣ថ្មី និងត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (តាមរយៈការប្រព្រឹត្តបទល្មើសសហចារី)[15]។

-ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ គឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត[16] (តាមរយៈការចូលរួមសហឧក្រិដ្ឋកម្មរួម)[17]។

## គ-ការផ្លាស់ប្តូរចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ

---

[13] ឯកសារ **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

[14] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D239 ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ និងឯកសារលេខ D239.1 ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

[15] ឯកសារលេខ D239.1 ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រង់កថាខណ្ឌ ៤-៥ និង ១០។

[16] ឯកសារលេខ D239.1 ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រង់កថាខណ្ឌ ៧ និង ៨។

[17] ឯកសារលេខ D239.1 ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រង់កថាខណ្ឌ ៦-៩ និង ១១។

13. ការស៊ើបសួរប្រឆាំងនឹង **អ៊ឹម ចែម** បានចាប់ផ្ដើមនៅក្រោមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde និងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង។[18] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde បានលាឈប់នៅខែវិច្ឆិកា ឆ្នាំ២០១០[19] និងត្រូវបានបន្តដោយលោក Siegfried Blunk។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានលាឈប់។[20] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានស្បថចូលកាន់តំណែងនៅចំពោះមុខកិច្ចប្រជុំពេញអង្គនៃ អវតក កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ មិនធ្លាប់បានតែតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាឡើយ។[21] ចៅក្រម Kasper-Ansermet បានសុំលាឈប់នៅខែមីនា ឆ្នាំ២០១២។[22] នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចៅក្រម Mark Harmon ត្រូវបានស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។[23] នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ចៅក្រម Mark Harmon បានប្រកាសនូវការលាឈប់របស់គាត់ និងត្រូវបានជំនួសដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander[24] រហូតដល់បច្ចុប្បន្ននេះ។”

## ឃ-សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹង “មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត”

[18] ឯកសារលេខ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។

[19] ឯកសារលេខ **D114** កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូនភាគីស្ដីអំពីភាពមិនអាចដំណើរការបានធូន់ធ្ងរដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤, ២១ មីនា ២០១២, កថាខណ្ឌ ១០ និង ១៧។

[20] សេចក្ដីប្រកាសព័ត៌មានរបស់ **អ.វ.ត.ក**, ‘សេចក្ដីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ១០ តុលា ២០១១។

[21] ឯកសារលេខ **D114** កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគីស្ដីអំពីភាពមិនអាចដំណើរការបានធូន់ធ្ងរដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤, ២១ មីនា ២០១២, កថាខណ្ឌ១០។ **D114.1** **អនុស្សរណៈ**របស់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ផ្ញើជូនសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet ខែធ្នូ ឆ្នាំ២០១១។

[22] សេចក្ដីប្រកាសព័ត៌មានរបស់ **អ.វ.ត.ក**, ‘សេចក្ដីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង, ១៩ មីនា ២០១២។

[23] ឯកសារលេខ **D217.1.4** ញត្តិបន្ទាន់ស្នើសុំដីកាបង្គាប់ចូលមើលសំណុំរឿង, ១៤ ធ្នូ ២០១២, កថាខណ្ឌ៤, សេចក្ដីប្រកាសព័ត៌មាន **អ.វ.ត.ក**, Mark Harmon បានស្បថចូលកាន់ដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ២៦ តុលា ២០១២។

[24] ឯកសារលេខ **D262** សេចក្ដីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្ដីពីការចេញឡើងវិញនូវដីកាសម្រេចដែលចៅក្រម Mark Harmon បានសម្រេចនៅ ឬថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, ៨ កញ្ញា ២០១៥, កថាខណ្ឌ១។

14. ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត លោក យូ ប៊ុនឡេង និង Mark Harmon បានអញ្ជើញភាគីទាំងអស់ ឱ្យដាក់សេចក្តីសង្កេតអំពីថាតើ អ៊ឹម ចែម គឺជា "មេដឹកនាំជាន់ខ្ពស់" ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩"[25]។

15. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាបន្ថែមមួយសប្តាហ៍ដើម្បីដាក់ការសង្កេតរបស់ខ្លួន ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតឱ្យដាក់សេចក្តីសន្និដ្ឋាន។[26] ជាមួយគ្នានេះដែរ សហមេធាវីការពារក្តី អ៊ឹម ចែម ក៏បានស្នើសុំពេលវេលាបន្ថែមចំនួនបួនសប្តាហ៍ដើម្បីដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន និងដាក់មួយភាសា[27]។

16. នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើសុំបន្ថែមពេលវេលា និងសុំដាក់មួយភាសា ដោយបានអនុញ្ញាតឱ្យភាគីដាក់សារណារបស់ខ្លួនរហូតដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ព្រមទាំងអនុញ្ញាតឱ្យដាក់សារណាជាភាសាអង់គ្លេសសិន ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[28]។

---

[25] សំណុំរឿងលេខ ០០៤/០១ ឯកសារលេខ D251 សំណើសុំដាក់សេចក្តីសន្និដ្ឋានថាតើ អ៊ឹម ចែម គួរចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេត។

[26] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/1 សំណើសុំបន្ថែមពេលវេលា និងដាក់មួយភាសាដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត សុំឱ្យដាក់សេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹង អ៊ឹម ចែម ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៥។

[27] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/2 ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពន្យារពេលបន្ថែមទាក់ទងនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការដាក់សារណាលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥។

[28] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/3 ដីកាសម្រេចលើសំណើសុំបន្ថែមពេលវេលា និងសុំដាក់មួយភាសា ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេត។

17. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ភាគីទាំងអស់បានដាក់សេចក្តីសង្កេតរបស់ខ្លួនជូនសហចៅក្រមស៊ើបអង្កេត ជាពិសេស សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្តីសង្កេតនេះ ដោយបានលើកឡើងថាសហព្រះរាជអាជ្ញាជាតិនៅតែរក្សាជំហរថា ជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងនោះរួមមាន អ៊ឹម ចែម ផងដែរ មិនមែនជា ***មេដឹកនាំជាន់ខ្ពស់*** និងមិនមែនជា ***ជនដែលទទួលខុសត្រូវខ្ពស់បំផុត*** *ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩* ពោលគឺមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ[29]។

18. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា អ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ឡើយ។ គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈឹម ឬគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។ តួនាទីខ្ពស់បំផុតរបស់គាត់គឺលេខាស្រុកនិងជាសមាជិកនៃគណៈកម្មាធិការតំបន់ ១៣ និងតំបន់ ១៥ រួមទាំង តួនាទីជាអនុលេខាតំបន់ ៥[30]។ ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា អ៊ឹម ចែម ស្ថិតនៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអត្ថន័យនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[31]។

19. សហមេធាវីការពារក្តី អ៊ឹម ចែម បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត សម្រេចថា អ៊ឹម ចែម មិនមែនជា "មេដឹកនាំជាន់ខ្ពស់" និងមិនមែនជាបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវ

---

[29] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/6 សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សចស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251 ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥។

[30] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/5 សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

[31] ដូចខាងលើ សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/5។

ខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការលើរឿងក្តីរបស់តុលាការនេះឡើយ និងសម្រេចបដិសេធការចោទប្រកាន់ទាំងឡាយមកលើ អ៊ឹម ចែម[32]។

## ង-ការបិទកិច្ចស៊ើបសួរ និងការបំបែកសំណុំរឿងលេខ០០៤/០១

20. ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគី អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម និងបានជូនដំណឹងភាគីទាំងអស់ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមផងដែរ (សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ)[33]។ ក្នុងថ្ងៃដដែលនេះដែរ សហចៅក្រមស៊ើបអង្កេត ក៏បានជូនដំណឹងដល់ភាគីទាំងអស់ អំពីគោលបំណងរបស់ខ្លួន ក្នុងការលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ (សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងចោទប្រកាន់)[34]។

21. ដោយហេតុថា មានភាពមិនច្បាស់លាស់រវាងសំណៅជាភាសាខ្មែរ និងភាសាអង់គ្លេស (ភាសាដើមទាំងពីរ) នៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងចោទប្រកាន់ ទើបនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើសុំការបញ្ជាក់ពីសហចៅក្រមស៊ើបអង្កេត ថាតើគោលបំណងរបស់សហចៅក្រមស៊ើបអង្កេតចង់**បំបែក**កិច្ចដំណើរការនីតិវិធី ឬក៏**បញ្ចប់**កិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម[35]។ បន្ទាប់មកសហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា ខ្លួនមានបំណងចង់បំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម[36]។

---

[32] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D251/4 សេចក្តីសង្កេតរបស់ អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា “មេដឹកនាំជាន់ខ្ពស់” ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ របស់សហមេធាវីការពារក្តី អ៊ឹម ចែម។

[33] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D285 សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេត។

[34] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេត។

[35] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/1 ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ របស់សហព្រះរាជអាជ្ញា អំពីសំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់លើសារណាដែលបានស្វែងរកដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណងរបស់ខ្លួនចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

[36] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/1/1 ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់សហចៅក្រមស៊ើបអង្កេត អំពីចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់អំពីសារណាដែលសហចៅក្រមស៊ើបអង្កេតបានស្នើសុំនៅក្នុងសេចក្តីជូនដំណឹងអំពីគោលបំណងរបស់ខ្លួនចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

22. នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ សហមេធាវីការពារក្ដី អ៊ឹម ចែម បានដាក់សារណាគាំទ្រចំពោះការបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង០០៤។[37] បន្ទាប់មកនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញា បានដាក់សេចក្ដីសន្និដ្ឋានអំពីការបំបែកសំណុំរឿងប្រឆាំង អ៊ឹម ចែម ដោយបានជូនដំណឹងថា ខ្លួនមិនជំទាស់នឹងការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម ទេ។ ប៉ុន្តែសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ នៅតែរក្សាគោលជំហររៀងៗខ្លួនអំពីថាតើ អ៊ឹម ចែម ស្ថិតក្នុងជំពូកបុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា[38]។

23. សហព្រះរាជអាជ្ញា បានស្នើនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនថា គប្បីអញ្ជើញភាគីឲ្យដាក់សារណា ឬសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរស្ដាពរ ក្នុងរយៈពេលបីខែ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញា ដោយមិនផ្ដល់ពេលវេលាឲ្យធ្វើចម្លើយតបនោះទេ[39]។ ប៉ុន្តែសហមេធាវីការពារក្ដី អ៊ឹម ចែម បានដាក់ចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋាននេះ ដោយស្នើសុំសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា[40]។

24. នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ ការិយាល័យសហព្រះរាជអាជ្ញាបានឆ្លើយតបថា ការដាក់សារណា និងសេចក្ដីសន្និដ្ឋានស្របពេលជាមួយគ្នា នឹងមិនធ្វើឲ្យភាគីណាមួយចាញ់ប្រៀបគ្នាទេ ហើយវានឹងពន្លឿនកិច្ចដំណើរការនីតិវិធីផងដែរ[41]។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្ដី សុំឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង[42]។

---

[37] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/2 ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់សហមេធាវីការពារក្ដី អ៊ឹម ចែម។

[38] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/3 សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់សហព្រះរាជអាជ្ញា។

[39] ដូចខាងលើ សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/3 ។

[40] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/3/1 ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ របស់សហមេធាវីការពារក្ដី អ៊ឹម ចែម។

[41] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/3/2 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ របស់សហព្រះរាជអាជ្ញា។

[42] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/6 ដីកាសម្រេចលើសំណើរបស់ អ៊ឹម ចែម ទាក់ទងនឹងការបិទកិច្ចការស៊ើបសួរ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់សហចៅក្រមស៊ើបអង្កេត។

25. នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿងលេខ០០៤ (ដីកាសម្រេចបំបែកសំណុំរឿង)[43]។ នៅក្នុងដីកាសម្រេចបំបែកសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា កិច្ចស៊ើបសួរលើការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម បានបញ្ចប់ហើយ ខណៈដែលកិច្ចស៊ើបសួរប្រឆាំងជនត្រូវចោទផ្សេងទៀតនៅក្នុងសំណុំរឿង០០៤ នៅតែបន្តដំណើរការដដែល[44]។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតបានសម្រេចបង្កើតសំណុំរឿងថ្មីដោយដាក់លេខ០០៤/០១ សម្រាប់ករណីជនត្រូវចោទ អ៊ឹម ចែម ព្រមទាំងបានជូនដំណឹងដល់ភាគីទាំងអស់អាចដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមប្រសិនបើមានបំណង[45]។

## ៣. ច្បាប់ជាធរមាន

26. ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក តម្រូវឱ្យតុលាការនេះ *ធ្វើការវិនិច្ឆ័យទោស និងជំនុំជម្រះលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩*[46] ។

## ៤. សេចក្តីសន្និដ្ឋាន

27. សហព្រះរាជអាជ្ញាជាតិ ប្រកាន់នូវជំហរថា ជនត្រូវចោទទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿងលេខ០០៤ មិនមែនជា ***មេដឹកនាំជាន់ខ្ពស់*** និងមិនមែនជា ***ជនដែលទទួលខុសត្រូវខ្ពស់បំផុត*** *ចំពោះ*

---

[43] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/7 ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ពីសំណុំរឿង០០៤ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់សហចៅក្រមស៊ើបអង្កេត។

[44] ដូចខាងលើ សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/7 ។

[45] ដូចខាងលើ សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286/7 ត្រង់កថាខណ្ឌ៨ និង ៩។

[46] មាត្រា ១ និងមាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក, និងមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

*ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩* ពោលគឺមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ[47]។ ដូច្នេះ សហព្រះរាជអាជ្ញាជាតិ សូមរក្សាឯកសារដែលបានដាក់ជូន ដូចមាននៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដដែល[48]។

28. យោងតាមច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក[49] និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (កិច្ចព្រមព្រៀង)[50] បានកំណត់យ៉ាងច្បាស់អំពីគោលបំណងនៃការបង្កើតសាលាក្តីនេះ គឺដើម្បីវិនិច្ឆ័យទោសតែទៅលើ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក តែប៉ុណ្ណោះ។

29. ការណ៍នេះបង្ហាញឲ្យឃើញថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង បានចង្អុលបង្ហាញអំពីតួនាទីរបស់ជនសង្ស័យដែលនឹងត្រូវយកមកធ្វើការវិនិច្ឆ័យទោស គឺមានតែពីរប្រភេទដូចបញ្ជាក់ខាងលើនេះ។ ចំណែកតួនាទីរបស់ជនត្រូវចោទដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងមិនមែនជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែលត្រូវយកមកវិនិច្ឆ័យសេចក្តីនៅ អ.វ.ត.ក នេះទេ។

30. សូមធ្វើការកត់សម្គាល់ថា សហព្រះរាជអាជ្ញាទាំងពីរ បានយល់ស្រប និងឯកភាពគ្នា ក្នុងការជ្រើសរើសជនសង្ស័យចំនួនប្រាំរូប[51] ដើម្បីធ្វើការចោទប្រកាន់ ដាក់ជូនសហចៅក្រមស៊ើបអង្កេត

---

[47] ដូចមានរៀបរាប់នៅក្នុងឯកសារលេខ 7 ស្តីពីចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន ៧១.២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ស្តីពីចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩។

[48] ដដែលដូចខាងលើ ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ។

[49] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក។

[50] មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

[51] នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, និង កាំង ហ្គេកអ៊ាវ ហៅ ឌុច។

គឺដោយសារជនសង្ស័យទាំងនេះ ត្រូវបានសហព្រះរាជអាជ្ញា កំណត់ថាជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ"[52] និងជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

31. ការកំណត់ជនសង្ស័យប្រាំរូបខាងលើនេះ ដោយសហព្រះរាជអាជ្ញាជាតិ យល់ឃើញថា៖

**នួន ជា:** គឺជាអនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក), ជាសមាជិកអចិន្ត្រៃយ៍ ប.ក.ក និងជាប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ និងមានតួនាទីជាច្រើនផ្សេងទៀត[53]។

**អៀង សារី:** គឺជាសមាជិកអចិន្ត្រៃយ៍ ប.ក.ក, ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងមានតួនាទីផ្សេងទៀត[54]។

**ខៀវ សំផន:** គឺជាប្រធានគណៈប្រធានរដ្ឋ និងជាសមាជិកគណកម្មាធិការមជ្ឈិម ប.ក.ក និងមានតួនាទីផ្សេងទៀត[55]។

**អៀង ធីរិទ្ធ:** គឺជាសមាជិកមជ្ឈិមបក្ស នៃ ប.ក.ក និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងមានតួនាទីផ្សេងទៀត[56]។

**កាំង ហ្កេកអ៊ាវ** ហៅ **ឌុច:** គឺជាប្រធានមន្ទីរសន្តិសុខ ស.២១ ដែលជាមន្ទីរសន្តិសុខ ដែលមានលក្ខណៈពិសេសជាងគេ និងមានភារកិច្ចផ្សេងទៀត[57]។

---

[52] មានបញ្ជាក់ជូនក្នុងឯកសារលេខ 17 ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ, កថាខណ្ឌទី៥២, ត្រង់ ERN 00329369 (ភាសាខ្មែរ)។

[53] មានបញ្ជាក់ជូនក្នុងឯកសារលេខ 17 ស្តីពី "ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៤ មេសា ២០០៩ និងសេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ, កថាខណ្ឌទី៤០, ត្រង់ ERN 00329360 (ភាសាខ្មែរ)។

[54] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329360-61 (ភាសាខ្មែរ)។

[55] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329361-62 (ភាសាខ្មែរ)។

[56] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329362-65 (ភាសាខ្មែរ)។

[57] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329365-66 (ភាសាខ្មែរ)។

32. ចំណែកឯ **អ៊ឹម ចែម** ដែលមានឈ្មោះក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាជាតិ យល់ឃើញថា មិនស្ថិតក្នុងតួនាទីជា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និងមិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ[58]។

33. យោងតាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌទូទៅ បណ្តឹងអាជ្ញាតម្រូវឲ្យមានការអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់។ ចំពោះច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺមានលក្ខណៈពិសេសខុសពីច្បាប់ទូទៅ ដោយហេតុថា ច្បាប់នេះតម្រូវឲ្យធ្វើការវិនិច្ឆ័យទោសតែលើជនពីរប្រភេទ[59] ដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ មានន័យថា ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺមានគោលបំណងធ្វើការកាត់សេចក្តី ដោយផ្សារភ្ជាប់ទៅនឹងការផ្សះផ្សារបង្រួបបង្រួមជាតិ និងជាពិសេស ដើម្បីទុកជាកេរ្តិ៍តំណែលឲ្យអ្នកជំនាន់ក្រោយបានដឹងអំពីព្រឹត្តិការណ៍ជូរចត់ និងសាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

34. បើពិនិត្យទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា មិនមែនមានតែ ក្នុងយុត្តាធិការរបស់ អវតក ទេ គឺមានតាំងពីសម័យរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយសេនាប្រមុខ លន់ ណុល មកម្លេះ។ ក្នុងរបបសាធារណរដ្ឋខ្មែរ ក៏មានការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ និងបានបណ្តាលឲ្យស្លាប់មនុស្សស្លាប់ ពិការភាព និងបណ្តាលឲ្យទ្រព្យសម្បត្តិ ផ្ទះសម្បែង ប្រជាជនត្រូវខូចខាតយ៉ាងដំណំជាច្រើនកន្លែងផងដែរ[60]។ ដូច្នេះ ការកំណត់របស់ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង មិនបានបំពេញទៅតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌទេ។

35. ដូច្នេះ សហព្រះរាជអាជ្ញាជាតិ ប្រកាន់យកការផ្សារភ្ជាប់ទៅនឹងបុព្វកថានៃកិច្ចព្រមព្រៀង ដែលតម្រូវឲ្យសហព្រះរាជអាជ្ញា គិតគូរដល់ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ មុននឹងធ្វើការប្តឹងចោទប្រកាន់[61]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាជាតិក៏នៅតែរក្សាជំហរដូចមាននៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដដែល ជាពិសេស គោលការណ៍យុត្តិធម៌ និងការផ្សះផ្សារបង្រួបបង្រួម

[58] ឯកសារលេខ 17 ដូចខាងលើ, កថាខណ្ឌទី៤០, ត្រង់ ERN 00329366 (ភាសាខ្មែរ)។

[59] មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

[60] ទស្សនាវដ្តីស្វែងរកការពិតលេខ ៣ ចុះខែមិថុនា ឆ្នាំ២០០០ ទំព័រទី៩។

[61] កថាខណ្ឌទី ២ នៃបុព្វកថា នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

ជាតិ[62] គោលបំណងរបស់ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង[63] នីតិវិធីអនុវត្ត[64] ការស៊ើបអង្កេតបឋម[65] និងការចោទប្រកាន់បែបសម្រិតសម្រាំង[66] ដែលជាយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួនជាដើម[67]។

36. ដូច្នេះឃើញថា លទ្ធផលតាំងពីដំបូងនៃការស៊ើបសួរបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងរហូតដល់ការបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាជាតិ យល់ឃើញថា ជនត្រូវចោទដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ០០៤/០១នេះ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ ដោយហេតុថា ជនត្រូវចោទនេះ **មិនមែនជាមេដឹកនាំជាន់ខ្ពស់** និង**មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត** ដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដូចមានចែងក្នុងច្បាប់ អ.វ.ត.ក ទេ[68]។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតក៏បានជូនដំណឹងដល់ភាគីនៃទាំងអស់ថា ខ្លួនមាននិន្នាការចង់លើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ដោយសារកង្វះយុត្តាធិការបុគ្គលដែរ[69]។

37. ថ្វីត្បិតតែការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម មិនអាចរកសម្លេងបានគ្រប់គ្រាន់នៅដំណាក់កាលអង្គបុរេជំនុំជម្រះ ដែលបានតម្រូវឲ្យមានការស៊ើបសួររហូតមកដល់ដំណាក់កាលនេះក៏ដោយ ក៏សហព្រះ

[62] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៨, ៩, ១០, ១១, ១៤, ១៥ ត្រង់ ERN 00267949-53 (ភាសាខ្មែរ)។

[63] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៨, ៩, ១០, ១១, ១៤, និង ១៥, ត្រង់ ERN 00267963-66 (ភាសាខ្មែរ)។

[64] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី៤២-៤៩, ត្រង់ ERN 00267966-68 (ភាសាខ្មែរ)។

[65] ឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌទី១៨, ១៩, ២០, ២១, ២២, ៣២, ត្រង់ ERN 00329352-57 (ភាសាខ្មែរ)។

[66] ឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌទី១៨, ១៩, ២០, ២១, ២២, ៣២, ត្រង់ ERN 00329323-00329324។

[67] ឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌទី២៤ ដល់ ៤១, ត្រង់ ERN 00267956-63 (ភាសាខ្មែរ)។

[68] ដូចមានបញ្ជាក់ជូននៅក្នុងឯកសារលេខ 7 ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ និងឯកសារលេខ 17 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ដូចខាងលើ។

[69] សំណុំរឿងលេខ ០០៤/១ ឯកសារលេខ D286 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សហចៅក្រមស៊ើបអង្កេត។

រាជអាជ្ញាជាតិ នៅតែយល់ឃើញថា ជនជាប់ចោទដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត ក៏មានបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ដោយសារកង្វះយុត្តាធិការបុគ្គលផងដែរ[70]។

## ៥. សំណើ

38. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាជាតិ សូមដាក់ជូនសំណុំរឿងលេខ០០៤/០១នេះ ទៅសហចៅក្រមស៊ើបអង្កេត និងស្នើឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចលើកលែងចោទប្រកាន់ **អ៊ឹម ចែម** តាមវិធាន ៦៧(៣)(ក) នៃវិធានផ្ទៃក្នុង។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |

[70] សំណុំរឿងលេខ ០០៤/១, ឯកសារលេខ D286 សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ត្រង់កថាខណ្ឌ ៧ របស់សហចៅក្រមស៊ើបអង្កេត។